# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូជុប (រួមទាំងដីវង)

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពី ការអនុវត្តន៍ព្រះរាជក្រម ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និងក្រុមហ៊ុនជលផល

-បានឃើញកិច្ចសន្យាទិញ និង កិច្ចសន្យាជួល សំរាប់ចំការកៅស៊ូជុប ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប ខូអិលធីឌី

-តាមសំណើរបស់គណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

## ស ម្រេ ច

**មាត្រា ១** : បញ្ចប់ស្ថានភាពគតិយុត្តិចំការកៅស៊ូជុប ដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ចាប់ពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

**មាត្រា ២** : ផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូជុប (រួមទាំងទីរង) ទៅឱ្យក្រុមហ៊ុន **សុភក្តិនីកា អ៊ិនវេសមេន គ្រុប ខូអិលធីឌី** (SOPHEAK NIKA INVESTMENT GROUP CO., LTD.) ដើម្បីបន្តគ្រប់គ្រង ស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាទិញ និង កិច្ចសន្យាជួលសំរាប់ចំការកៅស៊ូជុប ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន **សុភក្តិនីកា អ៊ិនវេសមេន គ្រុប ខូអិលធីឌី** (SOPHEAK NIKA INVESTMENT GROUP CO., LTD.) ចាប់ពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

**មាត្រា ៣** : រំសាយក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូជុប បញ្ចប់ដំណែងប្រធានអគ្គនាយកចំការកៅស៊ូជុប និង បញ្ចប់ដំណែងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូជុប ចាប់ពីថ្ងៃ ទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

**មាត្រា ៤** : ផ្ទេរឯកឧត្តម **ម៉ក់ គីមហុង** ប្រធានអគ្គនាយកចំការកៅស៊ូជុប ចូលមកបំរើការងារក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទវិញ ចាប់ពីថ្ងៃ ទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

**មាត្រា ៥** : ចំការកៅស៊ូជុបត្រូវប្រគល់ត្រា និងឯកសារពាក់ព័ន្ធទាំងអស់រួមទាំងឯកសារក្នុងកុំព្យូទ័រ មកគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសម្ភារៈកសិកម្ម និង ក្រុមហ៊ុនជលផល ដើម្បីរក្សាទុក ។

**មាត្រា ៦** : ថវិកាដែលនៅសល់ក្នុងគណនី និង បេឡា របស់ចំការកៅស៊ូជុប ត្រូវផ្ទេរចូលថវិការដ្ឋ ។ បិទរាល់គណនីធនាគារទាំងអស់របស់ចំការកៅស៊ូជុប ចាប់ពីថ្ងៃ ទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

**មាត្រា ៧** : អនុក្រឹត្យលេខ ១៤ អនក្រ-បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូជុប ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

**មាត្រា ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចក្នុងមាត្រា ៨*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*